**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

**សារលិខិតអបអរសាទរ**
**ខួបលើកទី៤៣ នៃទិវាជ័យជម្នះ ៧មករា**

**សូមគោរពជូន**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចវិបុលសេនាភក្តី ជាទីគោរពដ៏ខ្ពង់ខ្ពស់**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីសោមនស្សរីករាយឥតឧបមា ចំពោះខួបលើកទី៤៣ នៃទិវាជ័យជម្នះ ៧មករា ដែលជាថ្ងៃរំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីការកាប់សម្លាប់ក្នុងមហាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបើកឡើងនូវសករាជថ្មីនៃកម្ពុជា។

យើងខ្ញុំសូមសម្តែងនូវអំណរសាទរ ប្រកបដោយកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចវិបុលសេនាភក្តី** ដែលក្រោមការដឹកនាំប្រកបដោយបញ្ញាញាណដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចវិបុលសេនាភក្តី** បានធ្វើឱ្យស្ថាប័នព្រឹទ្ធសភា ដែលជាស្ថាប័ននីតិប្បញ្ញត្តិកំពូលរបស់ជាតិ សម្រេចបាននូវសមិទ្ធផលធំៗជាច្រើន រួមចំណែកយ៉ាងសំខាន់ដល់ការរក្សាបាននូវសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍឥតឈប់ឈរ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសប្រទានជូន **សម្តេចវិបុលសេនាភក្តី និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបាននូវពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ ពុធ ៣ កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh